# រោគសញ្ញារលាកពហុប្រព័ន្ធ ចំពោះកុមារ (MIS-C)

## តើរោគសញ្ញារលាកពហុប្រព័ន្ធ ចំពោះកុមារ គឺជាអ្វី?

រោគសញ្ញារលាកពហុប្រព័ន្ធចំពោះកុមារ (MIS-C) គឺជាស្ថានភាពសុខភាពថ្មីមួយ ដែលមានការពាក់ព័ន្ធជាមួយនឹងជំងឺ COVID-19 ដែលកំពុងលេចឡើងចំពោះកុមារ។ រោគសញ្ញានេះ ពីមុនត្រូវបានគេហៅថា រោគសញ្ញារលាកពហុប្រព័ន្ធកុមារ ឬ PMIS។

MIS-C គឺដូចជាស្ថានភាពរលាកធ្ងន់ធ្ងរដទៃៗទៀត ដូចជា [ជំងឺរលាកសសៃកាវ៉ាសាគី ឬ Kawasaki Disease] និងរោគសញ្ញាឆក់ពុល (toxic shock syndrome)។ កុមារដែលមាន MIS-C អាចមានបញ្ហាជាមួយបេះដូង និងសរីរាង្គនានាដទៃទៀតរបស់ពួកគេ ហើយត្រូវការទទួលនូវការព្យាបាលនៅមន្ទីរពេទ្យ។

MIS-C គឺជាស្ថានភាពដ៏កម្រមួយ។ ទោះជាយ៉ាងណាក៏ដោយ ដោយសារតែកុមារដែលមាននូវរោគសញ្ញានេះ អាចធ្លាក់ខ្លួនឈឺធ្ងន់ធ្ងរ, វាជាការសំខាន់ដែលឪពុកម្តាយ ត្រូវដឹងពីសញ្ញា និងរោគសញ្ញានានា ដែលកូនៗរបស់ពួកគេអាចមាន, ដើម្បីអោយពួកគេ អាចទទួលបាននូវជំនួយភ្លាមៗ។

## តើសញ្ញា និងរោគសញ្ញានានា នៃជំងឺ MIS-C មានអ្វីខ្លះ?

កុមារភាគច្រើនមានគ្រុនក្តៅ (សីតុណ្ហភាព ១០០.៤ ដឺក្រេ F ឬ ៣៨.0 ដឺក្រេ C ឬខ្ពស់ជាងនេះ) ដែលមានរយៈពេលជាច្រើនថ្ងៃ, រួមជាមួយរោគសញ្ញាផ្សេងៗទៀត។

រោគសញ្ញាទូទៅ រួមមាន៖

- ឆាប់ខឹង ឬថយចុះនូវសកម្មភាព
- ឈឺពោះ ដោយគ្មានការពន្យល់ផ្សេងទៀត
- រាគ
- ក្អួត
- កន្ទួល
- ជំងឺភ្នែកក្រហម (ភ្នែកពណ៌ក្រហម ឬផ្កាឈូក)
- បរិភោគមិនបាន
- បបូរមាត់ប្រេះ ឬក្រហម, អណ្តាតរដិបរដុប ឬមិនរាបស្មើ ដែលមើលទៅដូចជាស្ត្របឺរី
- ហើមដៃ និងជើង, ដែលអាចពណ៌ក្រហមផងដែរ

## តើពេលណាខ្ញុំគួរទូរស័ព្ទទៅវេជ្ជបណ្ឌិត របស់កូនខ្ញុំ ឬទទួលការថែទាំបន្ទាន់?

សូមទូរស័ព្ទទៅកាន់វេជ្ជបណ្ឌិតរបស់កូនអ្នកជាបន្ទាន់ ប្រសិនបើកូនរបស់អ្នកក្តៅខ្លួនជាប់រហូត បូកជាមួយនឹងរោគសញ្ញានានាខាងលើ។ វេជ្ជបណ្ឌិតនឹងសួរអំពីរោគសញ្ញានានាដែលកូនអ្នកមាន ហើយប្រើប្រាស់ព័ត៌មាននោះ ដើម្បីណែនាំនូវ ជំហានបន្ទាប់។ ប្រសិនបើកូនរបស់អ្នកឈឺធ្ងន់ធ្ងរ, សូមទៅកាន់បន្ទប់សង្គ្រោះបន្ទាន់ដែលនៅជិតបំផុត ឬទូរស័ព្ទទៅលេខ ៩១១ ជាបន្ទាន់។

## តើជំងឺ MIS-C ឆ្លងឬទេ?

MIS-C មិនឆ្លងទេ, ប៉ុន្តែអាចមានលទ្ធភាពថា កូនរបស់អ្នកមានជំងឺ COVID-19 ឬការឆ្លងមេរោគផ្សេងទៀត ដែលអាចឆ្លងបាន។ នេះជាមូលហេតុដែលមន្ទីរពេទ្យ នឹងចាត់វិធានការណ៍ត្រួតពិនិត្យការឆ្លងមេរោគ នៅពេលធ្វើការព្យាបាលកូន អ្នក។

## តើមានការព្យាបាលជំងឺ MIS-C ឬទេ?

បច្ចុប្បន្ននេះ, កុមារដែលមានជំងឺ MIS-C កំពុងត្រូវបានព្យាបាលដោយវិធីព្យាបាលផ្សេងៗគ្នា, រួមមានទាំងថ្នាំនានា ដែលផ្តោតលើប្រព័ន្ធភាពស៊ាំរបស់រាងកាយ និងការឆ្លើយតបទៅនឹងការរលាក។ កុមារអាចទទួលថ្នាំនានាដទៃទៀត ដើម្បីការពារបេះដូង, តម្រងនោម និងសរីរាង្គផ្សេងទៀត របស់ពួកគេ។

## តើខ្ញុំអាចការពារកូនរបស់ខ្ញុំ ពីការឆ្លងជំងឺ MIS-C យ៉ាងដូចម្តេច?

អ្នកគួរតែចាត់វិធានការណ៍ដើម្បីការពារកូនរបស់អ្នក ពីការប៉ះពាល់នឹងជំងឺ COVID-19។ ការគ្រប ឬបិទបាំងមុខ, ការធ្វើអនាម័យដៃ និងការឃ្លាតឆ្ងាយរាងកាយពីគ្នា គឺជាមធ្យោបាយដ៏ប្រសើរបំផុត ដើម្បីការពារជំងឺ COVID-19។ កុមារដែលមានលក្ខណ្ឌវេជ្ជសាស្ត្រ ឬជម្ងឺរ៉ាំរ៉ៃ អាចមានហានិភ័យខ្ពស់ចំពោះលទ្ធផលមិនល្អនៃការការពារជំងឺ COVID-19, ដែលធ្វើអោយវិធានការណ៍ការពារ រឹតតែសំខាន់។